# សារៈសំខាន់របស់សំដី

## *THE IMPORTANCE OF SPEECH*

សំដីនិយាយ មានសារៈសំខាន់ណាស់សំរាប់មនុស្សយើងគ្រប់គ្នា។ បើយើងប្រើពាក្យសំដីត្រូវ ល្អ នឹងកើតមាសកើតប្រាក់ តែបើយើងប្រើពាក្យសំដីខុស មិនល្អ នឹងកើតសត្រូវ ហិនហោចទ្រព្យ។ មេដឹកនាំពិភពលោកទាំងឡាយមិនដែលប្រើប្រាស់កំឡាំងកាយឬកំឡាំងទ្រព្យតែម្យ៉ាងទេ ដើម្បីសម្រេចនូវជោគជ័យរបស់គេ តែគេប្រើពាក្យសំដីដើម្បីទាក់ទាញ បញ្ចុះបញ្ចូល ពន្យល់ណែនាំអោយសហជីវិនធ្វើកិច្ចការតាមដោយសេចក្តីរីករាយនិងស្មោះត្រង់។ ដោយភាពមានមហិទ្ធិឫទ្ធិរបស់សំដីនេះឯង ទើបបុព្វាចារ្យខ្មែរប្រាប់យើងថា“ មុននឹងនិយាយចូរលាស់អណ្តាតឱ្យបានមួយរយដុំសិន” ព្រះពុទ្ធជាម្ចាស់តែងតែប្រើពាក្យសំដីដើម្បីទេសនាប្រៀនប្រដៅអោយសព្វសត្វទាំងឡាយបានសម្រេចនូវធម៌គឺព្រះនិព្វាន។ព្រះអង្គបដិបត្តិស្មើរតែគ្រប់ពេលវេលា គ្រប់ទីកន្លែងទាំងអស់ថា មនុស្សបានសុខ ឬទុក្ខ ឡើងឋានសួគ៌ឬធ្លាក់នរក ព្រោះអាស្រ័យពាក្យសំដីទាំងការនិយាយស្តីនិងការស្តាប់ពាក្យសំដី ពិភពលោកទាំងមូលមានសន្តិភាព ឬជួបប្រទះតែសង្គ្រាមក៏ព្រោះតែសំដី។ ក្នុងសិក្ខាបទសីលទី៤ព្រះពុទ្ធទ្រង់ត្រាស់អំពីទោសនៃការនិយាយកុហក់។ក្នុងអកុសលកម្មបទ១០ វចីកម្មមានរហូតដល់បួនគឺមុសាវាទា=និយាយកុហក់, បិសុណាវាចា=និយាយញុះញង់អោយគេបែកបាក់គ្នា, ផរុស្សវាចា=និយាយពាក្យមិនពីរោះពិសារ និងសម្ផប្បលាវាចា=និយាយពាក្យរោយរាយឥតប្រយោជន៍ ឬខ្មែរនិយមហៅថាតិរច្ឆានគាថា។ នៅក្នុងបរាភវសូត្រព្រះអង្គត្រាស់ថា “ អ្នកដេកច្រើនមួយ <u>អ្នកនិយាយច្រើនមួយ</u> និងអ្នកឥតព្រួយឥតគិតប្រឹងប្រែង ខឹងច្រើនសំដែងអោយគេដឹងបាន នោះជាប្រធាននៃក្តីវិនាស” ។ នៅក្នុងសង្គហធម៌បួន បិយវាចា គឺសំដីត្រូវ សំដីពីរោះពិសារ សំដីធ្វើឱ្យមនុស្សចេះស្រលាញ់គ្នា សំដីដែលនាំមកនូវប្រយោជន៍ ត្រូវបានព្រះអង្គត្រាស់មុនគេ ដើម្បីសង្គ្រោះដល់មនុស្សលោកទាំងមូល។

ជាពិសេសទានដែលព្រះពុទ្ធអង្គទ្រង់សរសើរជាងគេគឺបិយវាចាឬការនិយាយប្រកបដោយធម៌ ដូចដែលពុទ្ធភាសិតថា " សព្វទានំ ធម្មទានំ ជិនាតិ" ប្រែថា " ការអោយព្រះធម៌ (ការទេសនាប្រៀនប្រដៅ)ជាទាន ឈ្នះអស់ទានទាំងពួង" ។

ចំណែកបុព្វជន បុរាណាចារ្យឬអ្នកប្រាជ្ញទាំងឡាយរបស់ខ្មែរយើង ក៏ឱ្យយើងយកចិត្តទុកដាក់រឿងពាក្យសំដីអោយខ្លាំងមុននឹងនិយាយឬបន្លឺវាចាអ្វីមួយ ដូចដែលយើងសង្កេតឃើញសុភាសិតខ្មែរដូចតទៅនេះ :

- អណ្តាតជាអាទិ៍កន្លង បានសុខទុក្ខផងព្រោះតែអណ្តាត ។
- សំដីសជាតិ មាយាទសព្វូជ ។
- មនុស្សយកសំដី ដំរីយកភ្លុក ។
- សំដីជាឯក លេខជាទោ អក្សរជាត្រី ។
- រនាបបាក់យកឬស្សីជោះ សំដីនិយាយហួសគ្មានអ្វីជោះបាន ។

ដូច្នេះ ដើម្បីសេចក្តីសុខ សេចក្តីចំរើននៃបច្ចេកបុគ្គល និងអត្ថប្រយោជន៏នៃមហាជនទាំងឡាយ តើយើងមានវិធីនិងយុទ្ធសាស្រ្តយ៉ាងណាក្នុងការប្រើពាក្យសំដី ឬនិយាយស្តីម្តងៗ ?

ដោយ ***ព្រះភិក្ខុសេង សុផ័ណ***